**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**

លេខៈ ០៥១/...ន.៣
២០១៦

# សេចក្តីប្រកាសព័ត៌មាន

អនុវត្តតាមការអញ្ជើញរបស់ **បណ្ឌិត ចន ឆីបម៉ែន** (John Chipman) អគ្គនាយក និងជាប្រធានប្រតិបត្តិការនៃវិទ្យាស្ថានអន្តរជាតិសម្រាប់សិក្សាយុទ្ធសាស្ត្រ នៃសាធារណរដ្ឋសឹង្ហបុរី គណប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិដឹកនាំដោយ **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** នៃព្រះរាជាណាចក្រកម្ពុជានឹងអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលសន្តិសុខអាស៊ីលើកទី១៥ ( The 15th Asia Security Summit IISS Shangri – La Dialogue) ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៣ ដល់ទី០៥ ខែមិថុនា ឆ្នាំ២០១៦ នៅសាធារណរដ្ឋសឹង្ហបុរី ។

កិច្ចប្រជុំកំពូលសន្តិសុខអាស៊ីលើកទី១៥ រួមមានសម័យប្រជុំពេញអង្គ និងសម័យប្រជុំពិសេសដែលផ្តល់នូវវិសាលភាពសម្រាប់កិច្ចពិភាក្សាដ៏ទូលំទូលាយទៅលើនិន្នាការសន្តិសុខតំបន់សំខាន់ៗ ដូចជាអនុញ្ញាតឲ្យពិនិត្យពិច័យយ៉ាងពិស្តារលើប្រធានបទទាក់ទងទៅនឹងតំបន់នាពេលបច្ចុប្បន្ននេះ ។

**ឯកឧត្តម នាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់** អមដំណើរដោយប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិនឹងធ្វើមាតុភូមិនិវត្តមកកាន់ព្រះរាជាណាចក្រកម្ពុជាវិញនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៦ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦

នាយកដ្ឋានព័ត៌មាន